**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**

លេខ: ៤០៤/០២០ អអរ

## សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ដំណើរការ និងនីតិវិធី នៃគម្រោងហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម (SME)"

ព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី «**ដំណើរការ និងនីតិវិធីនៃគម្រោងហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម** (SME)» ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម វង់ ស៊ីលាំ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តម កៅ ថាច អគ្គនាយក នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**
- **Mr Dexter Tan Beng Kong អគ្គនាយក SME Bank នៃសហគ្រាសធុនតូច និង មធ្យម**
- **ព្រមទាំងមន្ត្រីជំនាញពាក់ព័ន្ធ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីដំណើរការ និងនីតិវិធីពាក់ព័ន្ធនានា នៃគម្រោងហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដើម្បីទទួលបានឥណទានមានការប្រាក់ទាប សម្រាប់ជំរុញបន្ថែមដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមឱ្យមានលទ្ធភាពគ្រប់គ្រាន់ចូលរួមវិភាគទានដល់កំណើនសេដ្ឋកិច្ច បង្កើតការងារ និងចំណូលជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដើម្បីបំពេញតម្រូវការក្នុងស្រុក ដែលជាកត្តាស្នូលលើកកម្ពស់សក្តានុពលសេដ្ឋកិច្ចជាតិ។

### I. គោលការណ៍ទូទៅ

ដើម្បីគ្រប់គ្រងផលប៉ះពាល់ ស្តារ និងជំរុញកំណើនសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានបន្តរៀបចំវិធានការ និងគិតគូរអំពីគោលនយោបាយអន្តរាគមន៍ ក្នុងការធានានិរន្តរភាពសេដ្ឋកិច្ច និងសង្គមកិច្ច។ ដើម្បីគាំទ្រការទទួលបានហិរញ្ញប្បទានរបស់ SMEs រាជរដ្ឋាភិបាល បានផ្តល់ហិរញ្ញប្បទានពិសេសចំនួន ៥០លានដុល្លារ ដល់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម, បង្កើតគម្រោងសហហិរញ្ញប្បទានចំនួន

១០០លានដុល្លារ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលចូលរួមចំនួន៣៣ ផ្តល់ដើមទុន ២០០លានដុល្លារ សម្រាប់បង្កើតសាជីវកម្មធានាឥណទានកម្ពុជា និងបានត្រៀមថវិកាចំនួន ៣០០លានដុល្លារ ដើម្បីគាំទ្រ និងដើរតួជាកាតាលីករជំរុញកំណើនសម្រាប់វិស័យសំខាន់ៗ។

ការគាំទ្រ SME គឺជាគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាល ដើម្បីរក្សាកំណើន សេដ្ឋកិច្ចជាតិ រួមមាន៖ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ, យុទ្ធសាស្ត្រ និងគោលនយោបាយជាតិ, ក្របខណ្ឌស្ថាប័ន, មូលនិធិ និងជំនួយបច្ចេកទេស។

រាជរដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានពិសេសចំនួន ៥០លានដុល្លារ តាមរយៈ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដើម្បីផ្តល់ឥណទានមានការប្រាក់ទាប ដោយផ្តោតលើអតិថិជន គោលដៅរួមមាន៖

- ប្រជាកសិករ សហគមន៍កសិកម្ម ក្រុមអ្នកផលិត ក្រុមអ្នកដាំដុះបន្លែ ផ្លែឈើ ចិញ្ចឹមសត្វ និងវារីវប្បកម្ម
- សិប្បកម្ម សហគ្រាសធុនតូច និងមធ្យម សហគមន៍កសិកម្ម ដែលស្ថិតក្នុងវិស័យកែច្នៃ ផលិតផលកសិកម្ម
- សហគ្រាសដែលនាំចេញផលិតផលសម្រេច និងពាក់កណ្តាលសម្រេច។

ចំពោះអតិថិជនដែលបានទំនាក់ទំនង និងស្នើសុំឥណទាន បានកើនឡើងដល់ ៤៣០នាក់គិត ត្រឹមថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ដែលមានទឹកប្រាក់សរុបប្រមាណ ៤២លានដុល្លារ។ ទឹកប្រាក់ដែលឥណទានបានអនុម័តមានចំនួនសរុប ១១.៣៧៨.០០០ដុល្លារ ផ្តល់ដល់អតិថិជន ចំនួន ៩៨នាក់។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម មានតួនាទីជាធនាគារគោលនយោបាយ និងពាណិជ្ជកម្ម ក្នុងការផ្តល់ហិរញ្ញប្បទាន ដើម្បីគាំទ្រការអភិវឌ្ឍក្នុងវិស័យអាទិភាព និងមានភារកិច្ចសំខាន់ៗ ដូចជា៖

- ផ្តល់ហិរញ្ញប្បទានក្នុងលក្ខខណ្ឌអនុគ្រោះដល់ SME ដែលមានលក្ខណៈសមស្រប
- ផ្តល់គោលនយោបាយគាំទ្រដល់ SMEs
- ទទួលប្រាក់បញ្ញើ និងផ្តល់សេវាទូទាត់ប្រាក់។

## II. បញ្ហាប្រឈម និងដំណោះស្រាយ

ក្នុងការជំរុញផ្តល់គម្រោងហិរញ្ញប្បទានពិសេស ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម មាន បញ្ហាប្រឈមដូចជា៖ កង្វះទ្រព្យធានា និងមិនទាន់បានចុះបញ្ជី ឬទទួលស្គាល់ដោយស្ថាប័នមាន សមត្ថកិច្ច។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បាន អនុវត្តតាមយន្តការរួមមាន៖ សហការជាមួយអ្នកធានាឥណទាន និងបន្ធូរបន្ថយ[illegible]។

## III. សម្គាល់

- រាជរដ្ឋាភិបាល បានត្រៀមថវិកាបន្ថែមចំនួន ៣០០លានដុល្លារ ពីប្រភពថវិកាជាតិ ដើម្បីគាំទ្រ និងជាកាតាលីករជំរុញកំណើនសេដ្ឋកិច្ចសម្រាប់វិស័យសំខាន់ៗ ក្នុងអំឡុងពេលមានវិបត្តិ និងក្រោយវិបត្តិ ដោយគ្រោងនឹងបង្កើតក្រុមប្រឹក្សាគោលនយោបាយដើម្បីដឹកនាំ សម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់គម្រោងហិរញ្ញប្បទាន។

- ធនាគារសហគ្រាសធុនតូច និងមធ្យម (SME Bank) បាននិងកំពុងអនុវត្តគម្រោងសហហិរញ្ញប្បទាន ក្នុងទំហំទឹកប្រាក់សរុប ១០០លានដុល្លារ ក្នុងបដិភាគស្មើគ្នា ជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូចូលរួមចំនួន ៣៣ ដើម្បីផ្តល់ឥណទានដែលមានការប្រាក់ទាបដល់ SMEs នៅក្នុងវិស័យអាទិភាពសំដៅជួយជំរុញសកម្មភាពផលិតកម្ម ក្នុងដំណាក់កាលនៃវិបត្តិកូវីដ១៩។ ការផ្តល់ហិរញ្ញប្បទាននេះ ក៏ជួបប្រទះនឹងបញ្ហាអត្រាការប្រាក់ខ្ពស់ និងកង្វះទ្រព្យបញ្ចាំ និងអាជីវកម្មក្រៅប្រព័ន្ធរបស់ SMEs ផងដែរ។៚

ថ្ងៃសុក្រ ១១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០